ទស្សនាវដ្ដី        លេខ ៤

# ពុទ្ធិកវិទ្យាល័យ



សង្កាត់លេខ៦ ភ្នំពេញ
ចណ្ណាធិការ ហ៊ួត-ចៀម

1956
គ 127
ឝ 127 ឝ

# មាតិការឿង


| | | | |
|---|---|---|---|
| បណ្ណាធិការ . . . . . . | ឆ្នាំថ្មី | ទំព័រទី | ១ |
| បណ្ឌិត សម-សុខុម . . . | ពុទ្ធទស្សនៈ (ត) | „ | ៤ |
| . . . . . . | ជំណឿសាសនា | „ | ៩ |
| មហា មាស-ចន. . . : . | ប្រវត្តិសង្ខេបនៃនាលន្ទា | „ | ១៤ |
| លោក កែវ-ហន់ . . . . | ពុទ្ធប្បវត្តិ | „ | ១៨ |
| . . . . . . | សេចក្ដីកត់ហេតុមហាសន្និបាត | „ | ២០ |
| មហា ជោង-ទិត . . . . | ស្ថានការណ៍នៅសហភាពភូមា | „ | ២៤ |
| ភិក្ខុ អាំ-សួន (ហៅហម) . | រចនាវិលាសភាសាអង់គ្លេស | „ | ២៦ |
| លោក ព៉យ-ប៊ុក . . . . | រឿងតុក្កតាធ្វើពីទង់ជាតិ (ត) | „ | ២៧ |
| លោក តែ-ជុន . . . . . | ជ័យព្រាជ្ញ (ត) | „ | ២៩ |
| លោក សួន-ស៊ិន្ទ . . . . | បុណ្ណកុមារ (ត) | „ | ៣២ |
| . . . . . . | ប្រវត្តិក្មេងកំព្រា | „ | ៣៥ |


## ដំឡៃជាវ

| ក្នុងប្រទេស | | | ក្រៅប្រទេស | | |
|---|---|---|---|---|---|
| ៦ ខែ | ១ ឆ្នាំ | ១ ក្បាល | ៦ ខែ | ១ ឆ្នាំ | ១ ក្បាល |
| ៥០៛០០ | ១០០៛០០ | ១០៛០០ | ៦០៛០០ | ១២០៛០០ | ១៣៛០០ |

## អ្នកទទួលឲ្យជាវ

សូមផ្ញើចំពោះទៅលោក ម៉ៅ-ម៉ី ធ្វើការនៅក្រសួងមហាផ្ទៃ ក្រុងភ្នំពេញ

ADRESSE: Monsieur Mao-Mey Ministère de L'Intérieur P.Penh





សួស្ដីបងស្វា! ខ្ញុំលាសិនហើយណា!

«ទេ! ឈប់សិន» ស្វាឆ្លើយ, «យើងមិនទាន់បានពិភាក្សាការណ៍គ្នាផង! ម្ដេចក៏គ្រាន់តែលេចមុខខ្ញុំភ្លាមក៏ស្រាប់តែលាទៅហើយ! ឈប់សិនអេះ! យើងនៅមានការណ៍និយាយគ្នាទៀតមុននឹងបងឯងថយចេញពីដំណែងនេះ»

«ចុះមានការណ៍អីទៅ!» ពពែឆ្លើយ

— «ម៉េចក៏ឆាប់ដាច់អាំក្បៃស្នាខ្ញុំម៉េះ? បងឯងរើយញាទេ នៅតាមដើងក្នុំកបទីបុកគោ ស្នាខ្ញុំកំពុងតែលួតាលោះសយ៉ាំងខ្សៀវបំពង់ - បន្ទាប់ពីក្បៀងផ្អាក់ពីរបីមេក្រោយនេះ! យើស! ចាំពីសា

សៀវភៅនោះសិន ឯខ្ញុំមិនសូវជាត្រូវការប៉ុន្មានទេ អាដែនសៀវភៅនោះបងតាំតែអើយ! បើបេក ពង់មានន័យ ៗ ខ្ញុំហើយ!

— ខ្ញុំត្រូវការណាស់ដែរ សៀវភៅខ្ញុំបងស្ងា តែថាទាស់បន្តិច បើសិនជាខ្ញុំខំប្រព្រឹត្ត ឲ្យច្រើនទៅ ក៏វាច្រើនតែពកក្រុសមិនសូវបានសុខក្នុងខ្លួនសោះ មួយថ្ងៃ ៗ រវល់តែឈឺពោះរកធ្វើការអ្វីក៏មិនបាន!

— មកពីបងឯងពិសាបេះតែឲ្យជ្រុល បានជាថាអ្វីង បើពិសាត្រឹមតែល្មម ៗ ទៅ នោះវាស្រួលខ្លួនទៅហើយ យើងក៏មានកម្លាំងកំហែងគ្រប់គ្រាន់ព្រោះតែជាតិជីវរស់នោះផង ហើយធ្វើការអ្វីធំដុំទៀតក៏បេះតែបានសម្រេចទាំងអស់ ៗ តែណ្ហើយចុះបងពៅតែ យើងកុំនិយាយការឥតប្រយោជន៍ច្រើនពេក មុននឹងបងឯងទៅ ត្រូវប្រគល់សំណុំរឿងផ្ទាំចាស់ឲ្យខ្ញុំមើលផង ដើម្បីនឹងខ្ញុំបានពិនិត្យឋានការណ៍របស់ប្រទេសយើងមើល តើវាមានល្បឿនប្តូរគ្នាយ៉ាងណាទៅ ១៤ ឆ្នាំកន្លងមកហើយនេះ!

— ឱ! បងស្ងា! តាំងពីបងឯងកាន់ហើយវិលត្រឡប់មកដល់ខ្ញុំវិញនោះ! ឃើញថាប្រទេសយើងផ្លាស់ប្តូរនយោបាយជាច្រើន ឥឡូវនេះប្រទេសយើងចូលដល់ឋានៈជាប្រទេសឯករាជ្យពេញលក្ខណៈហើយ អង្គការសហប្រជាជាតិគេបានយល់ព្រមឲ្យយើងចូលជាសមាជិកជំទង់គេហើយ យើងសព្វថ្ងៃនេះនៅបារម្ភតែបរិកាសម្រាប់ប្រទេសប៉ុណ្ណោះទេ! ព្រោះថាប្រទេសឯករាជ្យត្រូវតែលឿនទៅបាន អាស្រ័យមានថវិកាគ្រប់គ្រាន់សម្រាប់កសាងជាតិឲ្យចំរើនទាន់ប្រទេសសេរីនានា ៗ តែចំពោះសារនេះខ្ញុំនៅទុកចិត្តលើបងស្ងាឯងច្រើន ព្រោះប៉ុនប្រសប់ខាងផែនការរៀប ការជួយឲ្យថវិកាយើងមានគ្រប់គ្រាន់បាន; តែថាបងឯងកុំភ្លេចខ្លួនណា! បន្តិចទៀតបានបេកតនឹមានពិសាច្រើនហើយ

ក្ដុបខ្លួននោះ មុខជាយើងវិវរហើយ, ហើយម្យ៉ាងទៀតត្រូវយើងគិតដល់សាសនាយើងផង ព្រោះពេលពាក់កណ្ដាលសាសនាក៏គាន់តែកកិលចូលមកជិតហើយ ។

បងឯងដឹងទេ ភារៈរបស់យើងដែលធំបំផុតនៅលើសាសនា បើសាសនាយើងមិនសូវលឿនទៅមុខទេនោះ នយោបាយរបស់ប្រទេសយើងក៏ចេះតែខ្សោយទៅដែរ ហេតុនោះយើងត្រូវប្រយ័ត្នចក្ររបស់សាសនាផង ព្រោះចក្រនេះតែងតែវិលព្រមជាមួយនឹងចក្រផ្លូវលោក បើចក្រទាំងពីរនេះវិលមិនស្មើគ្នាទេ គួរថាប្រទេសជាតិដែលមានព្រះមហាក្សត្រជានាយសារថីនោះ នឹងក្លុកក្រឡាប់ក្នុងពេលណាមួយមិនខាន ត្រូវបងឯងប្រយ័ត្នបន្តិចណ៎ា ចំពោះរឿងនេះ ។

– អើ! បងពៅ! ចុះម្ដេចក៏បងឯងដាក់កំរិតខ្ញុំតឹងខ្លាំងម៉្លេះ បន្តិចលោថាខ្ញុំស្លាប់ខ្លួនកណ្ដាលផ្លូវទៅមិនទាំវិវរទៅហើយ!

– មិនដែលមាន! ពួកយើងសុទ្ធតែមានជីវិតចិត ធ្វើម្ដេចនឹងស្លាប់បាន!

– ទេ! មែន! ខ្ញុំក្ដុបបងពៅ បើទោះកុំភ័យចំពោះរឿងនេះខ្ញុំស៊ូដល់តែអស់ជីវិតផ្ទាល់ខ្លួន បើដូចនោះមុននឹងយើងបែកគ្នា ខ្ញុំសូមដំកល់មិត្តទាំងអស់ ដើម្បីជួយជាសាក្សីខ្ញុំផង ថាក្នុងឆ្នាំនេះខ្ញុំនឹងមិនលះបង់សេចក្ដីព្យាយាមខ្ញុំឡើយ ស៊ូលុះត្រាតែសម្រេចផលប្រយោជន៍ណាមួយដល់ប្រទេសជាតិរបស់យើង ។

– អើយ បើអញ្ចឹងយើងទាំងអស់គ្នាលាសិនហើយណ៎ា បងស្វាឯងនៅឲ្យបានសុខចុះ ហើយឲ្យបានសម្រេចដូចបំណង!

ជយោ បងស្វា!



ពុទ្ធទស្សនៈ (គ)

ទសពិធរាជធម៌ៈ

ទានំ សីលំ បរិច្ចាគំ អាជ្ជវំ មទ្ទវំ តបំ

អក្កោធំ អវិហឹសញ្ច ខន្តិញ្ច អវិរោធនំ ។

(ទានៈនឹងសីលៈ មិនបាច់អធិប្បាយទេ ព្រោះលោកអ្នកធ្លាប់ចេះដឹងមកហើយ)

-បរិច្ចាគំ ការលះទ្រព្យសម្បត្តិ ដើម្បីធ្វើជាប្រយោជន៍ដល់ប្រទេស ជាតិ សាសនា ឬដើម្បីប្រយោជន៍ដល់ភាគច្រើន ដូចជាសាងវត្ត សាងឱសថាគារ សាងពេទ្យព្យាបាលរោគ សាងសាលារៀន សាងថ្នល់ សាងស្ពាន ។ល។

៤- អាជ្ជវំ ការពោលពាក្យពិតទៀងទាត់ ការរក្សាពាក្យសត្យ;

៥- មទ្ទវំ ការមិនប្រឡោងខាម មិនប្រឡើសប្រើស, មិនប្រកាន់ខ្លួន ចេះគោរព ទន់លំទោនចំពោះវុឌ្ឍបុគ្គល គឺអ្នកដែលមានវ័យចំរើននិងមានគុណគឺសេចក្ដីល្អ ,

៦- តបំ ការបំពេញកម្មដុតកំដៅនូវកិលេស មានការរក្សាសីល៨រាល់ថ្ងៃឧបោសថ ជាដើម ,

៧- អក្កោធំ ការមិនធ្វើបុគ្គលដទៃឲ្យក្ដៅក្រហាយ ដោយសេចក្ដីក្រេវក្រោធ ,

៨- អវិហឹសំ មិនប្រព្រឹត្តការណាដែលជាផ្លូវបៀតបៀនដល់បុគ្គលដទៃ ,

៩- ខន្តិ: ការអត់ធន់ គឺអត់ធន់ចំពោះសេចក្ដីក្រោធនិងការប្រទូសរ៉ាយរបស់បុគ្គលដទៃ មិនប្រទូស្តតបបុគ្គលនោះវិញ ,

១០- អវិរោធនំ ការមិនប្រព្រឹត្តក្រៅទំនងក្នុងសាសនៈធម៌និងនីតិធម៌ ,

ទសពិធរាជធម៌ទាំង ១០ ប្រការនេះ កាលបើធៀបគ្នានិងបារមីទាំង ១០ ក៏ឃើញ



ៈដម្កល់ពានក្រុងភណ្ឌ

ត្រូវគ្នា ៣ ១ គឺ ទាន ១, សីល ១, ខន្តិ ១; ក្រៅអំពីនេះក៏សង្គ្រោះចូលក្នុងបារមីឯទៀតបាន គឺបរិច្ចាគៈ សង្គ្រោះចូលក្នុងទានបារមី, អាជ្ជវៈ សង្គ្រោះក្នុងសច្ចបារមី, មទ្ទវៈ សង្គ្រោះចូលក្នុងសីលបារមី, តបៈ សង្គ្រោះក្នុងវិរិយបារមី, អកោធៈ សង្គ្រោះចូលខន្តិបារមី, អវិហឹសៈ សង្គ្រោះចូលក្នុងមេត្តាបារមី, អវិរោធៈ សង្គ្រោះចូលក្នុងឧបេក្ខាបារមី ដូច្នេះឃើញថា: អ្នកដែលបានបំពេញទសពិធរាជធម៌ ហើយឈ្មោះថា: បានបំពេញបារមី៨ យ៉ាងក្នុងបារមីទាំង១០ ប្រការនោះ នៅសល់តែនេក្ខម្មបារមីនិងបញ្ញាបារមីប៉ុណ្ណោះឯង ៗ



ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់គង់លើរាជបល្ល័ង្កក្រោមមហាស្វេតឆត្រ័ ចាំទទួលការថ្វាយមុជរាជពីព្រះហស្តសម្តេច នរោត្តមសីហនុ ឧបយុវរាជ

ព្រះសម្ពុទ្ធជាម្ចាស់របស់យើង ទ្រង់បានបំពេញបារមី ៨ ប្រការ តាំងតែពីទ្រង់មិនទាន់បានចេញបព្វជ្ជានោះម៉្លេះ, លុះដល់ព្រះអង្គស្តេចចេញបព្វជ្ជា ទើបទ្រង់បំពេញ

នេក្ខមបារមីយ៉ាងលើសលប់, ហើយទ្រង់បំពេញបារមីឯទៀតៗ ឲ្យដល់នូវទីបំផុតជាលំដាប់ រហូតដល់បានត្រាស់ដឹងនូវធម៌ដ៏វិសេស បានព្រះនាមថា «សម្មាសម្ពុទ្ធ» ។



ព្រះមហាក្សត្រិយានីកំពុងយាងមកកាន់ព្រះសុវណ្ណកោដ្ឋ

កិច្ចការទីបំផុតនៃការត្រាស់ដឹងនោះ ព្រះបោរាណាចារ្យលោកសំដែងទុកក្នុងគម្ពីរមជ្ឈិមនិកាយថា: ព្រះអង្គទ្រង់ចំរើនសមថភាវនា ធ្វើចិត្តឲ្យជាសមាធិស្អាតបរិសុទ្ធ ប្រាសចាកឧបកិលេស គឺអារម្មណ៍ជាគ្រឿងសៅហ្មង ទ្រង់បំពេញជាលំដាប់ រហូតដល់នូវបញ្ញាទាំង ៣ ប្រការ បានកើតឡើងក្នុងយាមទាំង ៣ នៃរាត្រីតាមលំដាប់គ្នា ។

ដើម្បីបំពេញសេចក្ដីឲ្យចូលចិត្តដល់អ្នកដែលរៀនធ្លាប់នោះ សូមអធិប្បាយអំពីឈានទាំង ៤ ដែលចាត់ទុកដូចជាកាំជណ្ដើរជាដំណើរចាក់ធ្លុះដល់បញ្ញាឬញាណទាំង

ញដោយសេចក្ដីឆ្ងាយចូលចិត្ត ដូចតទៅនេះ ៖

ឈានៈ ការកំដៅអារម្មណ៍ ឲ្យចិត្តចុះរំងប់ក្នុងសមាធិ មិនឆាកវេរសាប់រសល់ បង្គាប់ចិត្តឲ្យនឹកចំពោះតែបំណងថៃលនឹក ៗ ឈាននោះចាត់ជាថ្នាក់មាន ៤ ហៅឈ្មោះតាមលំដាប់នៃអង្គ ៖



ព្រះមហាក្សត្រ និងព្រះមហាក្សត្រិយានី កំពុងយាងប្រទក្សិណនគរ .
ដែលមានក្បួនជង្ហែរយ៉ាងឧឡារិកតាមជង្ហែព្រះអង្គផង

## បឋមជ្ឈានមានអង្គ៥គឺ

១– នៅមានការត្រិះរិះ ហៅថាវិតក្កៈ ;

២– នៅមានការពិចារណា ហៅថាវិចារៈ, ដូចអារម្មណ៍របស់មនុស្សសាមញ្ញ តែមិនប្រកបដោយកិលេសកាមនិងអកុសលធម៌

៣– សេចក្ដីឆ្អែតចិត្ត ហៅថា បីតិ;

៤– សេចក្ដីសប្បាយចិត្ត កើតវិវេក គឺសេចក្ដីស្ងប់ហៅថា សុខ ;

៥– ចិត្តមានអារម្មណ៍តែមួយ នឹកចំពោះគន់របស់តែមួយមិននឹកដល់នេះ–ដល់នោះត្រូវឡប់ទៀនចុះ ហៅថា ឯកគ្គតា (នៅមានត)

# ដំណឹងសាសនា

## បុណ្យព្រហ្មទាន (ត)

បន្ទាប់មកព្រះដគុណពោធិវង្ស ប្រធានហ្សានពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត្យ ចាប់ផ្តើមថ្លែងសុន្ទរកថាមួយ មានសេចក្តីយ៉ាងពិស្តារដូចមានចុះក្នុងពត៌មានកម្ពុជាស្រាប់

ចប់សុន្ទរកថាហើយ ក៏ចាប់ផ្តើមធ្វើពិធីចែករង្វាន់ ដោយមានលោកទ្រិញ-ព៉ញ រដ្ឋមន្ត្រីក្រសួងឃោសនាជួយភារៈក្នុងការអញ្ជើញកៀវកិត្តិយសមានប្រគេនរង្វាន់ផ្ទាល់ ៗ ពិធីចែករង្វាន់ក៏បានចាប់ផ្តើមតាំងពីទី ១ រហូតដល់ទីបំផុត ដែលជាហេតុនាំមកនៅការហត់នឿយដល់លោកទ្រិញ-ព៉ញ ជារដ្ឋលេខាធិការក្រសួងឃោសនាការយ៉ាងក្រៃលែង រឿងនេះនាំឲ្យសមាគមអត់ទ្រាំមិនបានក៏សូមនាំមកនូវទឹកចិត្ត ដ៏ស្មោះស្ម័គ្រសំដែងសេចក្តីអរគុណយ៉ាងខ្លាំងបំផុត ដែលលោកបានស៊ូហត់នឿយជាមួយនឹងក្រុមយើងខ្ញុំ យើងខ្ញុំជឿជាក់ថា លោកជាខេមរៈបុត្រមួយរូបជឿស៊ប់ក្នុងព្រះពុទ្ធសាសនា យើងមានសង្ឃឹមតទៅទៀត ថានឹងបានលោកជាកិត្តិយសមួយយ៉ាងធំដល់សមាគមនេះតទៅថ្ងៃមុខទៀត ៗ យើងខ្ញុំសរសើរមិនអស់សោះ ព្រោះឃើញលោកនៅស៊ូនឹងកិច្ចការរបស់យើង ដូចជាក្រុមអភិបាលសមាគមដែរ ៗ ពិតមែនតែឥស្សរជនទាំងឡាយត្រឡប់ទៅអស់ហើយក៏ដោយ ក៏លោកនៅតែជួយយើងដែលឥស្សរៈជនមានសល់តែលោកមួយរូបប៉ុណ្ណោះ ក្នុងពេលចែករង្វាន់លើកទីពីរបានចប់ហើយ



ទីបំផុតនៃព្រះរាជពិធី ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់ថ្វាយសុទ្ធរកថាមួយគួរឲ្យចាប់ចិត្ត ហើយជាខ្លឹមសារយ៉ាងក្រៃលែង

ទីបំផុតសមាគមសូមថ្វាយព្រះរាជកុសល ចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងព្រះមហាក្សត្រិយានី សម្តេចព្រះសីហនុ នាយករដ្ឋមន្ត្រី លោកឧត្តមសេនាការបារាំង និងសម្តេច, ឯកឧត្តម, អស់លោក ព្រះថេរានុថេរៈ ដែលបានចូលមករួមក្នុងពិធីនេះក្តី មិនបានមកក្តី ក៏សូមឲ្យជួបប្រទះតែសេចក្តីសុខភាព និងសេចក្តីសម្រេចតាមគោលបំណងតទៅកុំបីឃ្លាងឃ្លាតឡើយ ។



# ការបំបួសកុលបុត្រ (ត)

## ម្ជុល

កាលភិក្ខុយកម្ជុលដេរស្បង់ចីពរ សង្ឃាដី ម្ជុលនោះហៅថា "កាយបរិហារ្យ" គ្រឿងរក្សាចិញ្ចឹមរាងកាយ ។ កាលភិក្ខុយកម្ជុលចាក់នុំចំណី ឬចាក់ផ្លែឈើឆាន់ម្ជុលនោះហៅថា "កុច្ឆិបរិហារ្យ" គ្រឿងរក្សាចិញ្ចឹមផ្ទៃ ។

## វត្តពន្ធចង្កេះ

កាលភិក្ខុយកវត្តពន្ធមកក្រវាត់រក្សាបរិមណ្ឌលឲ្យមាំ ហើយចេញដើរទៅក្នុងបន្ទោះស្រុក វត្តពន្ធនោះហៅថា "កាយបរិហារ្យ" គ្រឿងរក្សាចិញ្ចឹមរាងកាយ ។ កាលភិក្ខុទទួលអំពៅជាដើម ហើយយកវត្តពន្ធចងអំពៅបាច់មកឆាន់ វត្តពន្ធនោះ ហៅថា "កុច្ឆិបរិហារ្យ" គ្រឿងរក្សាចិញ្ចឹមផ្ទៃ ។

## ធមក្រក

កាលភិក្ខុយកធមក្រកដងទឹកស្រង់ ឬដងទឹកស្រោចប្រស់ព្រំទីសេនាសនៈ ធមក្រកនោះហៅថា "កាយបរិហារ្យ" គ្រឿងរក្សាចិញ្ចឹមរាងកាយ ។ កាលភិក្ខុយកធមក្រកដងទឹកឆាន់ឬទទួលដាក់អង្ករ អំបុកមកឆាន់ជាដើម ធមក្រកនោះហៅថា "កុច្ឆិ-បរិហារ្យ" គ្រឿងរក្សាចិញ្ចឹមផ្ទៃ ។

បរិក្ខារទាំង ៨ របស់អ្នកបួសមានប្រយោជន៍សម្រាប់ប្រើប្រាស់បានពីរៗ យ៉ាងដូចអធិប្បាយមកដោយសង្ខេបប៉ុណ្ណោះ ។

សូមនិគមបរិក្ខារទាំង ៨ ចងជាគាថាដើម្បីឲ្យងាយចាំ

តិចីវរញ្ចបត្តោច    វាសី សូចិ ច ពន្ធនំ



នេះជាក្បួនរថយន្តរាជហង្ស ជាជំនិះគណៈរដ្ឋមន្ត្រីសម្រាប់ដង្ហែក្បួនក្រទាំងពីរព្រះអង្គប្រទក្សិណរាជធានី

បរិស្សាវនេន អដ្ឋេតេ យុត្តយោគស្ស ភិក្ខុនោ ។

ប្រែថា: បរិក្ខារទាំង ៨ នេះ របស់ភិក្ខុអ្នកប្រកបព្យាយាមគឺ ត្រៃចីវរ បាត្រ កាំបិត ម្ជុល វត្ថពន្ធចង្កេះ ធមក្រក (តម្រងទឹក) ។

X

X X

## ពិធីបុណ្យពិសេសផ្សាយព្រះពុទ្ធសាសនានៅប្រទេសភូមានិងសៀម

ក្នុងវេលាកាលដែលអាត្មាភាពបានចេញចាកមាតុប្រទេសទៅបំពេញកិច្ចសិក្សាឯប្រទេសភូមានិងប្រទេសសៀម បានពិនិត្យនៅស្ថានការណ៍ជាច្រើន ផ្នែកសាសនាដែលមានការប្លែកពិសេសពីប្រទេសពុទ្ធសាសនាមួយទៅមួយ ៗ បណ្ដាហេតុការណ៍ទាំងនោះ ហេតុខ្លះមិនគួរទឹងជំពាប ដោយមិនមែនជាហេតុនាំមកនូវសេចក្ដីចំរើន ដូច្នេះ សូមអធិប្បាយដោយសង្ខេបចំពោះតែអត្ថបទខ្លះដែលប្រកបដោយសារៈប្រយោជន៍

ដូចតទៅនេះ៖

# ពិធីបុណ្យប្រចាំឆ្នាំក្នុងប្រទេសភូមា

នៅប្រទេសភូមា គ្រប់ៗវត្តអារាមដែលមានព្រះចេតិយ ឬ ពុទ្ធាគារ គេតែងតែមានចាត់ចែងការធ្វើពិធីបុណ្យនៅពេលមុនដាច់ឆ្នាំចាស់បន្តិចមួយថ្ងៃ ឬ ក្នុងពេលដែលចូលឆ្នាំថ្មីកន្លងទៅបានមួយថ្ងៃ ។ បុណ្យនេះហៅតាមភាសាភូមាថា «ផ្យាសតួយ» ប្រែថា «បុណ្យចេតិយ ឬ បុណ្យព្រះ» សេចក្ដីថា-បុណ្យនេះ មានន័យប្រហែលគ្នានឹងខ្មែរយើងថា «បុណ្យផ្កា» ដែរ ខុសគ្នាតែត្រង់ដែលគេធ្វើរាល់ឆ្នាំនឹងចំពោះតែថ្ងៃ-ខែ ដែលគេមានកំណត់ទុកយ៉ាងទៀងទាត់ ៗ ឧបមាថា បើគេធ្លាប់ធ្វើមកនៅថ្ងៃទី១៥



ឥស្សរៈជនគ្រប់តំណែងប្រដាប់កាយដោយគ្រឿងឥស្សរិយយស ដើរពីមុខរថយន្តរាជហង្ស ក្នុងក្បួនដង្ហែនេះ ដែលទឹកមុខញញឹមនឹងស្វាមីភក្ដិយ៉ាងក្រៃលែងចំពោះព្រះមហាក្សត្រថ្មីទាំងពីរព្រះអង្គ

កើតទៅផល្គុណ, តែដល់កាលវេលានោះហើយ គេក៏ចាត់ការផ្តើមធ្វើឡើង ។

របៀបចាត់ការធ្វើនោះ សុទ្ធតែគណៈកម្មការវត្ត ដែលព្រះសង្ឃទាំងឧបាសក-សិកាជើងវត្តបានតម្រូវឲ្យមានកម្មសិទ្ធិក្នុងការចាត់ចែងពិធីនោះ ក៏ចាត់ចែងការដោយខ្លួនឯង មិនមែនព្រះសង្ឃចាត់ចែងខ្វល់ខ្វាយឡើយ ។ ការចាត់វិធានការនេះ ដូចមានពយតៈ ៧:

ថ្ងៃទី១- គណៈកម្មការចាត់ការទិញវត្ថុជាច្រើនមុខ មាននាឡិកាដៃប្រុស-ស្រី, នាឡិកាពេជ្រ, នាឡិកាប៉ោល, កូយច្រើនបែប, គ្រឿងសិក្ខូបករណ៍នឹងវត្ថុផ្សេង ៗ ទៀតចំនួន២០ឬ៣០មុខ ហើយនឹងស្នើការប្រកាន់នូវរង់ឈ្មោះពេជ្រណាមួយដែលគេគាប់ចិត្តជាមុន ៗ ម្យ៉ាងទៀត មិនគ្រាន់តែមានវត្ថុប៉ុណ្ណោះទេ មានទាំងកំណត់ទឹកប្រាក់ផង ដូចជាកំណត់ថា ឆ្នោតរង្វាន់ទី១ត្រូវបានវត្ថុឈ្មោះនេះនឹងប្រាក់ចំនួនប៉ុណ្ណោះជាដើម (ចំនួន២០០ឬ៣០០ក្បាលតាមសមគួរ) ។ បន្ទាប់មក គេក៏ចាត់ការបោះពុម្ពសន្លឹកឆ្នោតចំនួន៨-៩ពាន់ឬ១ម៉ឺនសន្លឹក តាមគ្រោងការណ៍តូចនឹងធំនឹងបណ្ណកម្មវិធីបុណ្យ ដើម្បីលក់នឹងចែកផ្សាយទូទៅ ។ (នៅមានត)

---

## ប្រវត្តិសង្ខេបនៃនាលន្ទា (ត)

ប្រមាណជាង ៤០ ឆ្នាំមុននេះ ក្រុមបុរាណវត្ថុបានជីកកកាយប្រមូលផ្តុំនូវបម្លាក់បុរាណបានខ្លះឡើងវិញ រដ្ឋាភិបាលបានឲ្យសង់គ្រឹស្ថានពិពិធភណ្ឌមួយខ្នង សំរាប់ដំកល់បុរាណវត្ថុទាំងនោះ ដើម្បីកុំឲ្យបាត់បង់នូវស្នាដៃបុព្វបុរសជំនាន់នោះ ។ ចាងហ្វាងបុរាណវត្ថុបានបែងចែកវត្ថុជា ៤ ផ្នែកគឺៈពួកសិលាចារឹក ១ ផ្នែក, បដិមាករ ១ ផ្នែក,



គ្រឹះស្ថានសិក្សាសម្រាប់ព្រះសង្ឃនិងកុដិលំនៅបុរាណនៅនាលន្ទា
NĀLANDĀ

សញ្ញានឹងត្រាផ្សេងៗ ១ ផ្នែក, ពួកកុលាលភាជន៍ (គ្រឿងពែងប៉ាន់) ១ ផ្នែក ។ ក្នុងស្ថានពិពិធភណ្ឌនេះ មានព្រះពុទ្ធរូបខ្លះ, ព្រះពោធិសត្វ, ទេវតារបស់មហាយានខ្លះ នឹងកុលាលភាជន៍មានពែង, ប៉ាន់, ពាង, ក្រឡ, ឆ្នាំងជាដើម ។ ចានហ្វាងបុរាណវត្ថុបានយកបដិមាករ, សិលាចារឹកនឹងចម្លាក់ល្អៗខ្លះ ទៅតម្កល់តាំងទុកនៅស្ថានពិពិធភណ្ឌក្រុងបតៈ (បាតលីបុត្ត) ។ គ្រឿងរចនាប្រើនល្បីល្បាញខាងការសូចាក់ព្រះបដិមាករអង្គតូចៗ ល្អជាងអង្គធំៗ ។ រូបព្រះពោធិសត្វធ្វើល្អជាងគេ ដូចរូបព្រះពោធិសត្វឈ្មោះ បទុមបាណិ, អវលោកិតេស្វរៈ, វជីរបាណិ, មញ្ជុស្រីជាដើម ។ ឯសញ្ញារបស់មហាវិទ្យាល័យនាលន្ទាគេធ្វើជារូបធម្មចក្រនៅចន្លោះក្ដាន់ ១ គូ បត់ក្បាលមករកកន្ទុយ ។ នៅក្នុងស្ថានពិពិធភណ្ឌនេះ មានអក្សរចារឹកថា “ស្រីនា-លន្ទាមហាវិហារាយអារយភិក្សុសង្ឃស្យៈ ” ។

# វិជ្ជាស្ថាននាលន្ទាបច្ចុប្បន្ន



ថ្ងៃនឹងយប់បេះតែកន្លងទៅតាមចក្ករាសី មិនបេះឈប់ឈរ, អនិច្ចតាធម៌តែងសំដែងរូបរាងកាន់តែច្បាស់ឡើងៗ ប្រាកដដល់ចក្ខុនៃបណ្ឌិត គឺថាកាលបើមានកើតត្រូវមានស្លាប់ ស្លាប់ហើយតែងកើតឡើងវិញ, មានចំរើនត្រូវមានវិនាសៗ ហើយតែងចំរើនឡើងវិញ, ថ្ងៃនឹងយប់, បុណ្យនឹងបាបវឌ្ឍនកាលនឹងហាយនកាល ជាគូនឹងគ្នាផ្លាស់វេនគ្នាធ្វើការម្តងម្នាក់ វិលចុះវិលឡើងដូចកង់រទេះ រកទីបំផុតខាងដើមនិងខាងចុងឲ្យប្រាកដពុំបាន ។ មហាវិទ្យាល័យនាលន្ទា ដែលចំរើនរុងរឿងក្នុងបុរាណសម័យ ហើយដល់នូវមរណកាលគឺវិនាសសាបសូន្យប្រមាណជិត ៨០០ ឆ្នាំទៅហើយនោះ ក៏ចាប់បដិសន្ធិឡើងជាថ្មីម្តងទៀតក្នុងផ្ទៃនៃមាតា គឺភូមិប្រទេសដដែល ហើយប្រសូត្រចេញមកក្នុងរវាង ៤ ឆ្នាំមុននេះ ។

រដ្ឋាភិបាលរដ្ឋពិហារ (Bihar State) សម័យបច្ចុប្បន្ន (គឺដែនមគធៈសម័យបុរាណ) យល់ឃើញនូវប្រយោជន៍ដ៏សំខាន់ថា គួរសើរើសាងឡើងជាថ្មីនូវវិជ្ជាស្ថានសម្រាប់សិក្សាខាងពុទ្ធសាសនាត្រង់កន្លែងនេះ ដើម្បីកុំឲ្យសាបសូន្យស្នាមគំនូសចាស់ដែលធ្លាប់បានរុងរឿង, ក៏ប្រគល់ការដល់ព្រះមហាថេរ «កស្សប» ដែលលះបង់សាសនាហិណ្ឌូមកបួសក្នុងព្រះពុទ្ធសាសនា ឲ្យជាអ្នកផ្តើមគំនិតចាត់តាំងវិជ្ជាស្ថានសិក្សា

ឡើង ៗ ព្រះថេរៈកស្សប យល់ឃើញថាការតាំងលំនៅក្នុងទីនេះតែម្តង ជាហេតុលំបាកដល់ជីវភាពណាស់ ព្រោះភូមិនៅជិតនាលន្ទាសម័យបច្ចុប្បន្ននេះ ជាភូមិតូចតាច ច្រើនដោយវាលស្រែ ទើបលោកទៅតាំងទីសំណាក់ការបណ្តោះអាសន្ននៅក្រុងរាជគ្រឹះ ចម្ងាយ ១០ គ.ម. ខាងត្បូងនាលន្ទា ៗ លោកបានឲ្យគេជួសគ្រឹស្ថានសំណាក់បណ្តោះអាសន្នកាលពីខែសីហា ព.ស. ២៤៩៤ គ.ស. ១៩៥១ ៗ តមករដ្ឋាភិបាលបានអនុមតិប្រាក់ចំនួន ២ សែនរូពី ឲ្យសង់គ្រឹស្ថានសិក្សាជាស្ថាពរ ៗ ដំបូងលោកបានឲ្យសាងគ្រឹស្ថានតូចៗ នៅជិតស្ថានីយរថភ្លើងនាលន្ទាចម្ងាយប្រហែល ១៥០០ ម.ពីមហាវិទ្យាល័យចាស់, សម្រាប់ឲ្យនិស្សិតសិក្សាបណ្តោះអាសន្នសិន ទើបចាត់ឲ្យសង់គ្រឹស្ថានធំនៃវិជ្ជាស្ថាននៅខាងត្បូងមហាវិទ្យាល័យចាស់ចម្ងាយ ៥០០ ម. ៗ ពិធីបញ្ចុះបឋមសិលាបានធ្វើឡើងនៅថ្ងៃទី ១៩ វិច្ឆិកា គ.ស. ១៩៥១ ដោយមានបណ្ឌិតរាជេន្ទ្រ-ប្រសាទ ប្រធានាធិបតីប្រទេសឥណ្ឌាអញ្ជើញជាកិត្តិយសផង ៗ ការស្ថាបនាគ្រឹស្ថានក៏ចេះតែធ្វើបណ្តើរ, ការសិក្សាក៏បានតាំងស៊ប់តាំងពីឆ្នាំ ១៩៥៣ មក ៗ ដល់ខាងចុងឆ្នាំ ១៩៥៤ មុននេះគ្រឹស្ថានធំនៃវិជ្ជាស្ថានក៏ស្ថាបនាហើយស្រេច ព្រមទាំងមានភ្លើងអគ្គិសនីនិងទឹកម៉ាស៊ីនប្រើប្រាស់គ្រប់គ្រាន់ ៗ ការសិក្សាក៏បដិវត្តទៅបានស្រួល មានអ្នកសិក្សាល្អសមគួរ ៗ មានបណ្ណាល័យដ៏សម្បូរពោពាសដោយសៀវភៅជាភាសាផ្សេងៗ គឺភាសាបាលី, សំស្ក្រឹត, អង់គ្លេស, ហិណ្ឌី, មេង្គាលី, លង្កា, ចិន, ជប៉ុន, ទីបេត, ភូមា, សៀម, ខ្មែរ ៗ

ប្រទេសលង្កា, ភូមា, សៀម បានបញ្ជូនព្រះត្រៃបិដកព្រមទាំងអដ្ឋកថា, ដីកា, អនុដីកា មកឲ្យវិជ្ជាស្ថាននេះ ៗ

(នៅមានត)



ពុទ្ធប្បវត្តិ

(តពីទស្សនាវដ្ដីលេខ៣មក)

ថ្ងៃមួយមានជជិល នាមទេវិលគេទតាបស មកចូលគាល់ចំពោះ សូមមើលអង្គរាជកុមារ ។ រីអង្គព្រះមហាក្សត្រ ស្ដេចទ្រង់ពាត់ស្រីស្រឹង្គារ ឲ្យទាំពជកុមារ មកនមស្ការតាឥសី ។ ឯអស់នាងស្រីស្នំ នូវមេនំបមថមបី មកដាក់ក្បែរឥសី ស្រេចហើយស្រីថយគាយា ។ អង្គព្រះពោធិសត្វ យកព្រះបាទទាំងទ្វេហារទៅផាន់លើជដា

គឺកេសាក្បាលឥសី ៗ តាបសឃើញហេតុប្លែក ជាចំឡែកពីប្រក្រតី ទើបក្រោក
ឡើងចេញខ្ទី ព្រះឥសីនឹកអស្ចារ្យ ៗ ហើយគាំងថ្វាយបង្គំ ព្រះបរមរាជកុមារ ហើយ
មានបវរដីកា ថាមានបារមីច្រើនក្រៃ ៗ តាបសក៏ញញឹម ដោយសង្ឃឹមក្នុងហឫទ័យ
ស្រាប់តែឥសីថ្ងៃ យំវិញនៃជ្រប់កន្ត្រា ៗ ព្រះបាទសុទ្ធោទនធ្ងល់ មានពិភាល់ក្នុងចិត្ត
ក៏សួរឥសីថា ហេតុអ្វីណាក៏ដូច្នោះ ៗ តាបសឆ្លើយតបថា ឯអាត្មាញញឹមនោះ
ដោយនឹកស្មោះបំពោះ ដល់ឧរសថ្ងៃនេះឯង ៗ ថាមុខជាបានត្រាស់ ប្រាកដច្បាស់
ពុទ្ធិស្ងប់ស្ងែង ប្រោសសត្វសព្វកន្លែង ឥតថ្ងឹងថ្ងែងពេលកន្លង ៗ បានជាអាត្មាយំ
ស្តាយខ្លួនខ្ញុំចាស់ហើយហោង ពុំទាន់ព្រះច្បាស់ច្បង ត្រាស់ក្នុងនូវញាណញេយ្យ ៗ
បើសិនអាយុនៅ នឹងឃើញផ្លូវដោយប្រពៃ ក្តើម្តេចអាយុខ័យ នឹងក្សិណក្ស័យមុន-
សាស្តា ៗ តាបសថ្វាយព្រះពរ លាកូនទៅវិញណា និមន្តចូលអរញ្ញា ផ្ទៀបសម្រា
ក្នុងព្រៃជ្រៅ ។

ពិធីថ្វាយព្រះនាម

លុះគ្រប់ថ្ងៃប្រាំពីរ ព្រះភូមីទ្រង់ឲ្យហៅ ព្រាហ្មណ៍ព្រឹទ្ធចូលគាល់ហ្មៅ
រើសសំដៅប្រាំបីនាក់ ៗ ដែលឈ្លាសហោរាសាស្ត្រ ទាយទៀងណាស់គ្មានទិសទាក់
ឯព្រាហ្មណ៍ប្រាំពីរនាក់ មើលលក្ខណៈហើយទាយថា ៗ ប៉ុន្តែមុននឹងទាយ ព្រាហ្មណ៍
លើកថ្វាយម្រាមហត្ថា ម្រាមពីរជាប្រាស្នា ហើយទាយថាដូចតទៅ ៗ "រាជកុមារ-
នេះ មានដំរេះយ៉ាងជ្រាលជ្រៅ បើសិនជាគង់នៅ ក្នុងពិភពទៅបានស្តេចចក្រ ៗ
បើចេញបព្វជ្ជា បានពុទ្ធាពិតប្រត្យក្ស ត្រាស់ដឹងធម៌ជាក់លាក់ ជាពុំនាក់នៃសព្វ
សត្វ ៗ ឯព្រាហ្មណ៍កោណ្ឌញ្ញៈ កោរិទៈលើកម្រាមហត្ថ តែមួយហើយទាយថ្វាត់,

ព្រះមហាសត្វបួសមិនទាន ។ មុខជានឹងបានត្រាស ប្រាកដណាស់មិនតែងកាន

សម្បត្តិចក្រសោះខាន ច្បាស់ជាបានជាព្រះពុទ្ធ ។ ទើបអង្គពុទ្ធបិតា សួរព្រាហ្មណ៍

ថាតើអយ្យបុត្រ ឃើញហេតុអ្វីតក់ស្លុត បានជាបុត្រយើងចេញបួស ។ ព្រាហ្មណ៍

ទូលតបវិញថា ឃើញមនុស្សជរាពួស ទាំងមនុស្សឈឺ, ស្លាប់, បួស ដោយភ័យហួស

ទើបបព្វជ្ជា ។ រួចព្រាហ្មណ៍ប្រាំបីនាក់ មើលលក្ខណៈសព្វអង្គ ហើយថ្វាយព្រះនាមថា

«ព្រះសិទ្ធត្ថ» ថ្ងៃឧត្តម ។ ឯអង្គពុទ្ធបិតា ទ្រង់ចាត់ការដោយខះខំ ឲ្យសេនាតូចធំ

យាមព័ទ្ធជុំគ្រប់ទ្វារវាំង ។ បើឃើញមនុស្សជរា មនុស្សពិការត្រូវឃាត់ឃាំង មនុស្ស

ស្លាប់ឬស្គមស្គាំង ហើយថែមទាំងគេទបព្វជ្ជា ។ ប្រយ័ត្នក្រែងអយ្យបុត្រ ឃើញហើយ

ស្លុតក្នុងអង្គា ញាប់ញ័រហឫទយា ចូររាំងរកុំឲ្យស្គាល់ ។ (នៅមានត)

---

# សេចក្ដីកត់ហេតុនៃមហាសន្និបាត (ត)

លោក ចាប-ស៊ុំ បានពន្យល់ដោយសព្វគ្រប់អំពីច្បាប់នោះហើយក៏សុំថា ឲ្យទុករឿង

នេះតាមមាត្រាក្នុងលក្ខន្តិកៈនោះដដែលចុះ កុំកែប្រែអ្វីឡើយ ។

មហាសន្និបាតក៏បានមូលមតិគ្នាជាឯកច្ឆ័ន្ទថាកុំឲ្យកែប្រែត្រង់មាត្រាក្នុងលក្ខន្តិកៈនោះ

ឡើយ ។

៥– អំពីរឿងធ្វើមហាសន្និបាតត្រង់ប្រការលេខ ២៧ ជាមហាសន្និបាតដែលទុកជា

ត្រឹមត្រូវបានលុះតែសមាជិកដែលប្រជុំចំនួនពាក់កណ្ដាល បូកនឹងមួយ (១/២+១)

នៃចំនួនសមាជិកនៅក្នុំពេញក្នុងឆ្នាំនិមួយ ៗ ។ រឿងនេះមហាសន្និបាតពិភាក្សាដោយម៉ត់

ចត់អស់ពេលយ៉ាងយូរ ទើបសម្រេចទៅតាមយោបល់ភាគច្រើនថា “ទុកចាំមើលគ្នា-

តទៅមុខទៀតបើកាលណាចេះតែដូចឆ្នាំនេះសឹមគិតកែប្រែ ។

បន្ទាប់ពីនោះមកមហាសន្និបាត ក៏បានរៀបចំបោះឆ្នោតរើសក្រុមអភិបាលសម្រាប់ឆ្នាំ ១៩៥៦ ហើយលោក រ៉ាយ-ប៊ុក អតីតប្រធានទីដំណាងក្រុមអភិបាលចាស់បានប្រកាស ៣ ចប់ ទើបមហាសន្និបាតជ្រើសតាំង ឯ.ឧ.ឡាំ-ឯម នឹងលោកហួត-ហៀម លោកសូរ-ស៊ីផន ជាលេខាធិការបណ្ដោះអាសន្នក្នុងការបោះឆ្នោតពេលនោះ ។

លោកប្រធានក៏ចាត់ឲ្យសរសេរឈ្មោះក្រុមអភិបាលចាស់ នៅក្ដារខៀនខាងស្ដាំ; បេក្ខជនឈរឈ្មោះនៅក្ដារខៀនខាងឆ្វេង ।

លុះដល់លោកប្រធាន មើលឈ្មោះនៅក្ដារខៀនទាំងពីរ ឃើញមានបេក្ខជនចំនួនតែ១៥នាក់គឺ:

| | |
|---|---|
| លោក រ៉ាយ-ប៊ុក | លោកស្រី សមញាណ |
| " ផេង-គ្រីវ | " តៃ-ជុន |
| " ប៊ឹង-ហ៊ាត | " ទៅ- ម៉ី |
| " សូរ-ស៊ីផន | " ហួត-ហៀម |
| " ចាប-ស៊ុម | " ស្វាយ-រ៉ា |
| " អ៊ូច-ឯក | លោកស្រីរ៉ាយ-លុត |
| លោកស្រីរ៉ាយប៊ុក | អ្នកស្រីគង់-សរ |
| លោកអ៊ុក-ផង់ | |

មហាសន្និបាតបានឃើញដូច្នោះហើយក៏បានមូលមតិស្របគ្នាជាឯកច្ឆន្ទថា ពុំចាំបាច់ឲ្យមានការបោះឆ្នោតឡើយ ហើយយល់ឃើញចំនួនបេក្ខជនដូចខាងលើនេះគ្រប់អង្គជាក្រុមអភិបាលស្រាប់ទៅហើយ គឺអនុម័តយកអស់លោកទាំង១៥រូបនោះជាការស្រេចតែម្ដង ។

លុះរួចហើយអស់លោកជាសមាជិកសមាជិកា ដែលជាក្រុមអភិបាលថ្មីបានក្រោកឡើងទៅឈរតម្រៀបដើម្បីបង្ហាញមុខដល់មហាសន្និបាត ។ ក៏បានទះដៃទទួលអំណរយ៉ាងក្រៃលែង ។

ទើបក្រុមអភិបាលថ្មីបានកំណត់ពេលប្រជុំនៅថ្ងៃចន្ទទី៩ខែមករាគ.ស១៩៥៦ពេលម៉ោង៧និង៣០នាទី (ម៉ោង៥កន្លះល្ងាច) នៅមន្ទីរសំណាក់ការសមាគមដើម្បីនឹងចែកមុខការគ្នាតទៅទៀត ។

មហាសន្និបាតបានលើកពេលប្រជុំនៅម៉ោង១៨និង២៥នាទី (ម៉ោង៦, ៤៥ល្ងាច) តាមរបៀបវារៈនៃការធ្វើសន្និបាតដូចមានសេចក្ដីរៀបរាប់ខាងលើនេះ ។

## របាយមុខចំណូលនឹងចំណាយ

| លេខរៀង | ក) របាយមុខចំណូល | ប្រាក់ |
|---|---|---|
| ១ | ប្រាក់ដែលអគ្គាសបានពីសមាជិកប្រចាំឆ្នាំ | ២៨.៥១៥៛ |
| ២ | ប្រាក់ដែលបានពីកិរៃថវិកាសមាគម | ៩.៩០០៛០០ |
| ៣ | ប្រាក់ដែលបានពីសាខាសមាគមខេត្តក្រៅគឺកំពង់ឆ្នាំង នឹងតាកែវ | ៥.០៦៧៛០០ |
| ៤ | ប្រាក់ដែលបានពីបុណ្យផ្កាផ្សេង ៗ | ៥.៥៦១៛០០ |
| ៥ | ប្រាក់អំណោយពីសម្ដេចព្រះឧបយុវរាជ | ៩.០០០៛០០ |
| ៦ | ប្រាក់អំណោយពីសម្ដេចព្រះធម្មលិខិតឧត្ដមប្រឹក្សាវត្តលង្កា | ១.០០០៛០០ |
| ៧ | ប្រាក់ចំណូលពីទស្សនាវដ្ដី | ៤៤.៩៧០៛០០ |
| ៨ | ប្រាក់សល់ពីឆ្នាំចាស់ | ៨០.៥៤១៛៩៣ |
| | បូករួម | ១៨៤.៤៥១៛៩៣ |

| លេខរៀង | ១) ភាយមុខចំណាយ | ប្រាក់ |
|---|---|---|
| ១ | ប្រគេនសមណនិស្សិត ៣ អង្គទៅប្រទេសឥណ្ឌា | ៤៥.៩៨៣៛ |
| ២ | អំណោយបោះពុម្ពទស្សនាវដ្ដី ព្រមទាំងរូបថតនឹងថ្លៃ គិតតាំងពីខ្សែ ១ ទៅខ្សែ ៧ | ៦១.២៦៨៛ |
| ៣ | ថ្លៃផ្ញើទស្សនាវដ្ដីទៅប្រទេសក្រៅនឹងខេត្តក្រៅ | ៥.២០៥៛០០ |
| ៤ | ចំណាយផ្ញើបណ្ណព្រហ្មទានប្រគេនសមណនិស្សិតដែលប្រឡងចេញពីសាលាបាលីជាន់ខ្ពស់ | ៥.៤៣៥៛០០ |
| ៥ | បោះលិខិតផ្ញើមហាសន្និបាតឆ្នាំចាស់ | ៤០០៛០០ |
| ៦ | ទិញបង្គោលស៊ីម៉ង់ត៍ធ្វើរបងដីសមាគម | ២.៧៦៥៛០០ |
| ៧ | បោះពុម្ពបង្កាន់ដៃបណ្ដោះអាសន្ន | ១.០១៧៛០០ |
| ៨ | ចំណាយទិញគ្រឿងសម្ភារៈសម្រាប់ការិយាល័យសមាគម | ១.២០០៛០០ |
| ៩ | ប្រាក់បុគ្គលិក | ២១.២០០៛០០ |
| | បូករួម ១៤៥.២៧៣៛៥០ | |
| | ប្រាក់ចំណូលទាំងអស់ | ១៨៤.៤៥៤៛៩៣ |
| | ប្រាក់ចំណាយទាំងអស់ | ១៤៥.២៧៣៛៥០ |
| | ប្រាក់នៅសល់គង់ហិប | ៣៩.១៨១៛៤៣ |
| | ប្រាក់គេជំពាក់ថ្លៃទស្សនាវដ្ដីឆ្នាំនេះ | ៧៨.៥៣០៛ |
| | ប្រាក់គេជំពាក់ថ្លៃទស្សនាវដ្ដីឆ្នាំមុន | ២០.០០០៛០០ |

បូករួម ៩៨.៥៣០៛០០

# ស្ថានការណ៍នៅសហភាពភូមា (ត)

តាមកិច្ចស្នើការណ៍ ចេតិយ៍ស្វេតគន់នេះ គេកសាងយូរឆ្នាំណាស់មកហើយ ។ មានការរុះរើស្ថាបនាឡើងអស់វារៈ ៦ លើកមកហើយ សម្រាប់ដំកល់ព្រះពុទ្ធបរិក្ខារផ្សេង ៗ នឹងព្រះកេសធាតុ រវាងព្រះពុទ្ធ ៤ ព្រះអង្គមកហើយ គឺចាប់តាំងពីព្រះពុទ្ធ កកុសន្ធៈ កោនាគមនៈ កស្សបៈ នឹង គោតមៈ ។ ចេតិយ៍នេះ ធំយ៉ាងក្រៃលែងសាងអំពីឥដ្ឋវិចិត្រដោយក្បូរក្បាច់រចនាល្អល្អះពន្រាយ លាយចម្រុះដោយក្បាច់ក្ញីផ្កាសារពើសត្វ ស្ថិតនៅលើដំបូលយ៉ាងស្កឹមស្កៃ មានចេតិយ៍តូច-ធំប្រតិស្ឋានព័ទ្ធព័ទ្ធមីរដេរដាសដោយជុំវិញ កុះករដោយព្រះបដិមាករនៅគ្រប់ទិសានុទិស ។ មានមណ្ឌបតូច-ធំ លាបលនដោយទឹកសុវណ្ណបត្រផែរដោយផ្ទាំងសន្លឹកមាស កង់ទេវាពត្រីគេក្រឡេកឃើញកំពូលផ្កា ក្បូរក្បាច់រចនាព្រមទាំងពន្លឺភ្លើងអគ្គិសនីភ្លឺប្រាលរន្ទាលធ្អិនផ្អៅគួរឲ្យស្ញើចសរសើរយ៉ាងមហាស្ចារ្យ ហើយមានការពិភាល់អនេកអនន្តគណនាត្រាពប់ពុំបាន ដោយគិតថា « ចុះហេតុដូចម្ដេចបានជារដ្ឋាភិបាល ព្រមទាំងពលរដ្ឋនៃសហភាពភូមាអាចស្ថាបនាបូជនីយដ្ឋានដ៏ធំធេងកុះករយ៉ាងនេះទៅបាន ? បានប្រាក់មកពីណា កសាងបូជនីយដ្ឋានទាំងនោះ ដោយងាយម្ល៉េះ, ឆ្លើយ...ត្រង់កិច្ចនេះ បើពោលថាកសាងបានលំបាកក៏បាន ថាដោយងាយក៏បាន ចុះដោយឧបាយដូចម្ដេច ? តាមការពិនិត្យដោយជាក់លាក់ថា ចេតិយ៍ទាំងនោះបុរាណសម័យគេមិនមែនកសាងឲ្យធំមហាស្ចារ្យបែបដូចសព្វថ្ងៃនេះប៉ុន្មានតែម្ដងទេ គឺគេសាងពង្រីកម្ដងបន្តិច ៗ លុះត្រាតែធំធេងដូចបច្ចុប្បន្នសម័យនេះ បើដូច្នេះ តើគេបានប្រាក់មកពីណាកសាង ? ឆ្លើយថាហេតុដែលនាំឲ្យងាយកសាងវត្ថុទាំងនោះកើត ពីព្រោះគេប៉ុនប្រសប់រៀបចំគ្រោង

ការណ៍យ៉ាងម៉ឺងម៉ាត់ ហើយស្ថានពរថែមទៀតផង ព្រោះប្រជាជនប្រទេសគេពេញចិត្តគោរពបូជានមស្ការបូជនីយដ្ឋានទាំងឡាយ មានចេតិយព្រះស្តូប ព្រះបដិមាករទាំងនោះណាស់ ច្រើនតែបូជាប្រាក់កាសនិងផ្កាក្រពមទាំងទៀនដោយច្រើន (ឯធូបគេមិនសូវនិយមយកទៅបូជាទេ) ។ ត្រង់កន្លែងបូជនីយដ្ឋាននីមួយៗ តែមានសមាគមមួយក្រុមៗ ជាអចិន្ត្រៃយ៍ មានហិរញ្ញកោស ៦-៧ ដំកល់ទុកសម្រាប់ដាក់ប្រាក់កាស ដែលជាភាគទាននៃទាយកទាយិកា ។ នៅកន្លែងដំកល់ហិរញ្ញកោសនោះៗ មានអាចារ្យម្នាក់ៗ អង្គុយប្រចាំការជានិច្ច ចាំឲ្យពរស័ព្ទសាធុការនិងវាយជួងរគាំងទទួលត្រេកអរសាទរ ចំពោះបសាទិកជនទាំងឡាយ ដែលបានធ្វើការបូជា ។ អស់រយៈកាលរវាង ១ ខែ ឬ ២-៣ ខែក្រុមសមាគមទាំងនោះ ប្រមូលហិរញ្ញកោសទាំងនោះ បើកពិនិត្យត្រួតត្រាប្រាក់កាសទាំងអស់នោះម្តង បានលទ្ធផលប៉ុន្មានយកទៅទុក ១ កន្លែង (ជួនកាលបើប្រាក់នោះតិច គេយកទៅចងការយកកម្រៃថែមទៀតរាល់ខែ-ឆ្នាំជាលំដាប់តទៅ ។ តើប្រាក់ទាំងនោះ គេយកទៅប្រកបការងារអ្វី ? កសាងវត្ថុអ្វីក្រៅពីបូជនីយដ្ឋានទាំងនោះដែរឬ ? ។ ឆ្លើយថា — ទេ ប្រាក់ទាំងនោះ ត្រូវបាននៅកន្លែងណា គេត្រូវដំកល់ទុកដើម្បីស្ថាបនា ឬជួសជុលកន្លែងនោះ ឲ្យមានថាវរភាពនិងវឌ្ឍនភាពឡើង កុំពេលដែលវត្ថុទាំងនោះទ្រុឌទ្រោមទៅ ឬក៏ជួលកម្មករឲ្យបោសសំអាតទីកន្លែងនោះៗ ឲ្យស្អាតល្អឡើង ។ ព្រោះហេតុនោះហើយបានជាងាយដល់ការស្ថាបនាបូជនីយដ្ឋានផ្សេងៗ យ៉ាងកុះករហើយវិសេសវិសាលយ៉ាងនោះៗ បាន ។ ឯចេតិយដទៃនៅកន្លែងនានាក៏មានវិធានការណ៍ដ៏មុតមាំយ៉ាងដូច្នោះដែរ ។

(នៅមាន ត)

# រចនាវិសាសវិក្យ ភាសាអង់គ្លេស(ត)

មុនដំបូងនេះ សូមនាំរឿងមួយជាឧទាហរណ៍ដែលជាប់ទាក់ទងដល់ការមិនស្ទាត់ជំនាញខាងប្រយោគរចនាវិសាសនៃភាសាអង់គ្លេស ។

A certain Franchman weutto America. He, once, travelling by train, had heard someone nearby shout: «Look out!». He catched a sight out at the traie 13 window to see what was happening. At that moment a bucketful of water fell on him, and he was soaking wet.

មានជនជាតិបារាំងមួយរូបបានទៅកាន់ប្រទេសអាមេរិក ។ ម្ដងនោះ គាត់កំពុងធ្វើដំណើរដោយរថភ្លើង បានឮអ្នកជិតខាងស្រែកថា "Look out!" ។ គាត់ហោលក្បាលក្រឡេកមើលទៅខាងក្រៅតាមបង្អួចរថភ្លើង ដើម្បីរកមើលអ្វីដែលជាហេតុកើតឡើង ។ ពេលភ្លាមៗនោះ ស្រាប់តែទឹកពេញមួយធាំងធ្លាក់ស្រោចលើខ្លួនគាត់ទទឹកជោគ ។

(រឿងនេះ មកពីគាត់សំគាល់សេចក្ដីតាមសព្ទ "Look out!" ថាឲ្យ "ក្រឡេកមើលទៅខាងក្រៅ" ដោយមានហេតុអ្វីមួយកើតឡើង ។ តាមពិតនោះពាក្យ "Look out!" ជាពាក្យ Idiom ឲ្យប្រែថា "ប្រយ័ត្ន!, ប្រុងខ្លួន!" ។

ប្រយោគរចនាវិសាសនៃភាសាអង់គ្លេស ដែលខ្ញុំសរសេរនេះ គឺសរសេរតាមបែបអាមេរិកកាំង (ប្រហែលជាង ៤០ សព្វាយនៈ ទើបចប់), ខ្ញុំនឹងព្យាយាមសរសេរទាល់តែចប់ ហើយបើមានពេលនឹងសរសេរ តាមបែបរបស់អង់គ្លេសថ្មីមកបុះថែមទៀត ។

(នៅមានត)

# រឿងតុក្កតាធ្វើពីទធិជាតិ (ត)

ព្រះរាជនីសុខពនីក្រាបបង្គំទូលព្រះមហាក្សត្រថា:

“ ខ្ញុំម្ចាស់មិនបានទៅទទួលភារៈនោះទេ ; សេចក្ដីព្រួយបារម្ភរបស់ខ្ញុំម្ចាស់ជាភារៈធ្ងន់ណាស់ទៅហើយទ្រង់ត្រាស់បង្គាប់ឲ្យខ្ញុំម្ចាស់ទៅទទួលភារៈអ្នកឯទៀត ! មិនបានទេព្រះអង្គ ! ”

ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលថា:

“ ព្រះរាជនី , ម្ដេចក៏ដូចនោះ ? ម្ដេចក៏អូនឯងហ៊ាននិយាយបែបដូចនេះ ? នៅព្រះជានុ(ក្បាលជង្គង់)បង , មានព្រះរាជបុត្រាមួយព្រះអង្គឡើងប៉ុះកំសាន្តលេងសប្បាយ; នៅលើព្រះរាជបល្ល័ង្ករបស់បង , មានព្រះរជ្ជទាយាទមួយអង្គឡើងទៅគង់កងកាលជាអនាគត -... ។ មិនត្រូវធ្វើទឹកមុខក្រៀមក្រំទេ , អូន , បើយើងបានដំណឹងនេះគួរឲ្យសប្បាយពន់ពេក ! នែអូន ! , ថ្ងៃនេះនៅព្រះបរមរាជវាំង , មុខមនុស្សទាំងអស់បញ្ចេញសេចក្ដីរីករាយសប្បាយពន់ពេក , មានតែអូនមួយដែលទៅជាស្រងូតស្រងាត់ ។

ព្រះរាជនីក្រាបទូលព្រះមហាក្សត្រថា:

“ ទុក្ខប្រើនពេក , ខ្ញុំម្ចាស់លែងទទួលទុក្ខហើយ , ព្រះរាជបុត្រានាងនោះឡើងសោយរាជ្យជាស្ដេច , ព្រះរាជបុត្រីនាងនោះត្រូវគ្រប់គ្រងព្រះរាជអាណាចក្រ .. អ្នកនេះឡើងសោយរាជ្យ , នាងនោះមិនបានសោយរាជ្យ... យ៉ាងណាក៏ដោយ , ខ្ញុំម្ចាស់មិចង់រវល់ចង់ព្ដឹងឡើយ ; សេចក្ដីព្រួយបារម្ភរបស់ខ្ញុំម្ចាស់ល្មមហើយ ។ បើកូនអ្នកណាស្លាប់ (១) បុរសខ្ញុំម្ចាស់ក៏មិនត្រូវការចង់ដឹងព្ញុឡើយ ! ឱព្រះអាទិទេពអើយ ,

(១( ស្លាប់ ពោលពាក្យ (ស្លាប់) បំពោះទារកដែលរៀបប្រសូត្រឬព្រឹត្តិការណ៍សុខស្រួល , ឈ្មោះថាពោលពាក្យអាក្រក់ជាបំផុត ។

តាំងពីព្រលឹមទល់ព្រលប់ , ទ្រង់មានបន្ទូល , ទ្រង់មានបន្ទូលជានិរន្តរ ; ខ្ញុំម្ចាស់ទទួលទានដំណោកមិនបាន , តក្កូលខ្ញុំម្ចាស់ឈឺពន់ពេក . . . . ខ្ញុំម្ចាស់នឹងគិតទៅដូតទឹកបន្តិច . . . . » ។

ព្រះរាជិនីក្មេងទ្រង់តើនឡើងហើយទ្រង់ស្តេចទៅ , ដោយបង់បោយព្រះហស្តឲ្យស្ពាវល្បែងទាំងប្រាំបីគូរណ្តំពីពេះព្រមទាំងបន្ត្រីនៃនុបរៈទាំងដប់គូ , មានព្រះទ័យតោមនស្សជាខាំង ។

ព្រះមហាក្សត្រទ្រង់ព្រះពិរោធជាខ្លាំងដោយ , ក្នុងឱកាសដែលទ្រង់មានព្រះបន្ទូលពីព្រះរាជបុត្រា , ព្រះនាងសុខពនីពោលពាក្យ " ស្ងាប់ "... ។ ទ្រង់បានចាកចេញពីព្រះវែនរបស់នាងសេនាណៈ (Zénanah) ព្រះភ័ក្ត្រព្រួយពន់ពេក , ហើយយាងតម្រង់ទៅខាងបន្ទប់នៃព្រះបរមរាជកំគ្គិមាន ។

មហារាជនីនិព្រះរាជនីទ្រង់ទាស់ឈ្មោះគ្នា ; ព្រះមហាក្សត្រទ្រង់មិនបានទតឃើញព្រះភ័ក្ត្រនៃព្រះរាជនីក្មេង ; តែបើទុកជាយ៉ាងណាក៏ដោយព្រះមហាក្សត្រទ្រង់មិនយាងយាងទៅគេហដ្ឋានព្រះនាងទុក្កពនីទេ , ខ្លាចក្រែងព្រះនាងសុខពនីប្រចណ្ឌ , ទៅជាបំពុលព្រះនាងទុក្កពនី , ។

ព្រះមហាក្សត្រទ្រង់គង់តែមួយព្រះអង្គឯងនៅក្នុងព្រះបរមរាជកំគ្គិមានស្ងៀមក្រហមក្នុងប្រាលផ្ទៀងដូចមាស-... ។ មួយខែរួចពីរខែ... ក្រោយពីខែ , ខែទីបីទៀត , តែព្រះមហាក្សត្រ និងព្រះនាងសុខពនីទ្រង់មិនទាន់មានព្រះទ័យសុខស្រួលនឹងគ្នាឡើយ ; ទាំងអស់បួនខែហើយ , ដែលទ្រង់ព្រះពិរោធហើយទ្រង់មានព្រះទ័យមិនសប្បាយនឹងព្រះនាងសុខពនី ។ (នៅមានត)

# ជ័យប្រាជ្ញ (គ)

នៅវេលាថ្ងៃមួយព្រះមហាក្សត្រទ្រង់ចាត់ឲ្យប្រជុំនាហ្មឺនមុខមន្ត្រីសេនាបតីទាំងអស់នៅក្នុងរាជសភា ដើម្បីនឹងសម្រេចការផ្សេងៗក្នុងប្រទេស ។ ពេលប្រជុំនោះព្រះមហាក្សត្រទ្រង់ដាក់កំហិតឲ្យការនោះហើយស្រេចក្នុងថ្ងៃនោះ ព្រោះសុទ្ធតែជាការប្រញាប់ៗ ពួកនាហ្មឺនមុខមន្ត្រីសេនាបតី ព្រមទាំងសេវាមាត្យខ្លះ បាននាំគ្នាទៅប្រជុំតាំងព្រឹកទាំងល្ងាច ។ ការនោះក៏បានសម្រេចនៅពេលប្រលប់នាថ្ងៃនោះទៅ ។ នាហ្មឺនមុខមន្ត្រីដែលបានប្រជុំហើយក៏នាំគ្នាទៅកាន់ផ្ទះរៀងៗខ្លួន ។ កុមារជ័យនៅឈរវេរៗត្រង់ទ្វារចេញចូលនៃរាជសភា ដោយនៅរង់ចាំស្តាប់កិច្ចការផ្សេងៗខាងផ្លូវរាជការតាំងពីពេលបើកប្រជុំមក ព្រោះខ្លួនមិនដែលធ្លាប់ដឹងធ្លាប់ឮសោះ ។

អាមាត្យម្នាក់ដែលធ្លាក់រណ្តៅចេញរួចមកក្រោយគេពីថ្ងៃមុន មកដល់ថ្ងៃនេះដួនជាចេញមកក្រោយគេទៀត បានឃើញកុមារជ័យឈរវេរៗនៅក្បែរមាត់ទ្វារក៏មានចិត្តក្តៅក្រហាយខ្លាំង ស្ទុះទៅចាប់សក់កុមារជ័យជាប់បម្រុងនឹងទះកំភ្លៀង ២.៣.ដៃ ។ កុមារជ័យលុះត្រូវគេចាប់ក្របួចសក់ក្បាលដូច្នោះ នឹងឃើញភ្លាមថា ឱ! លោកនេះនឹងវាយអញហើយតើ! ក៏ស្រដីទៅកាន់អាមាត្យវិញភ្លាមថា ឱ! កុំអាលៗ ខ្ញុំនៅវេរៗនេះព្រោះតែការរបស់លោក!

អាមាត្យ — ការអី?

កុមារជ័យ — ការសំខាន់ណាស់លោក!

អាមាត្យ — អាឯងប្រាប់មកមើល?

កុមារជ័យ — ក្រែងតែលោកឈប់វាយខ្ញុំទើបប្រាប់បាន

អាមាត្យ — ប្រាប់មកអញសិន! ៗ

កុមារជ័យ — ការនោះជាលាភរបស់លោកយ៉ាងឆ្ងាញ់អស់ពីចិត្ត ៗ

អាមាត្យ — មើលលាភយ៉ាងឆ្ងាញ់ដូចម្ដេច!

កុមារជ័យ — លែងសក់ក្បាល់ខ្ញុំទៅទើបជំរាបបាន ៗ

អាមាត្យ — ប្រាប់មកអញសិនទើបលែង! ៗ

កុមារជ័យ — បើមិនលែងជំរាបមិនកើតព្រោះការនោះឆ្ងាញ់ហើយផ្អែមផង តែ-ធ្វើបាបខ្ញុំយ៉ាងនេះមុខជាខានពិសារហើយ ៗ

អាមាត្យ — អើ! បើដូច្នេះអញលែងឯងចូរឯងប្រាប់មកមើល ៗ

កុមារជ័យ — បាទ បើលែងឲ្យយ៉ាងនេះទើបជំរាបបាន ៗ

អាមាត្យ — ចូរអាឯងប្រាប់ឲ្យឆាប់មកកុំនៅឯអង់ប្រយ័ត្នត្រូវកំភ្លៀង

កុមារជ័យបេះតែថយបន្តិចម្ដងៗ ហើយថា អញ្ចុះ បើទះកំភ្លៀងខ្ញុំទៅខានបានឆ្ងាញ់តែម្ដង បើកុំ... យ៉ាងនេះក្រែងមានផ្លូវគ្រាន់បើ ៗ

អាមាត្យ — ណ្ហើយ! ឲ្យតែឯងប្រាប់មកអញមិនធ្វើអីទេ ៗ

កុមារជ័យ បាទ! អ្នកមេនាងស្រី ប្រើខ្ញុំឲ្យមកជំរាបលោកថាអ្នកមេនាងមានចិត្តប្រតិព័ទ្ធនឹងលោកខ្លាំងណាស់ បើលោកចេញមកសូមឲ្យលោកនូវវង់ចាំបន្តិច អ្នកមេ-នាងនឹងអញ្ជើញមកជួបសុំសេចក្ដីស្ន័គ្រ ៗ

អាមាត្យ — អើ! អីចឹងមែនឬ អាអូន! ៗ

កុមារជ័យ — បាទ! អីចឹងមែន!

អាមាត្យ — បើដូច្នេះ តើគិតយ៉ាងណា ?

កុមារជ័យ — ចាំខ្ញុំទៅដំរាបអ្នកមេនាងសិន ។

អាមាត្យ — អើ! អូនឯងទៅដំរាបចុះ បងនៅចាំជ្រុងកំផែងឯណោះ ។

កុមារជ័យបានដើរសំដៅទៅដំណាក់អ្នកមេនាងស្ត្រី ហើយនៅរើបន្តិចត្រឡប់មកវិញ ។ លុះមកដល់ហើយ

អាមាត្យនោះសួរថា ម៉េចអាអូន! ។

កុមារជ័យ ទាន! អ្នកមេនាងថាឲ្យលោកអញ្ជើញទៅចាំក្នុងបន្ទប់ទៅ បើនៅទីនេះក្រែងគេឃើញ អ្នកមេនាងនឹងអញ្ជើញមកជួបឥឡូវហើយ ។

អាមាត្យក៏ចូលទៅសម្ងំក្នុងបន្ទប់នោះយ៉ាងស្ងៀមស្ងាត់បាត់មាត់ឈឹង ។ បើទុកជាបន្ទប់ឲ្យចំហាយស្អុយយ៉ាងណាក៏ចេះតែទ្រាំអត់ ។

លុះអាមាត្យនោះនៅសំងំបានជាមួយស្របក់ កុមារជ័យរត់ឡេវមកប្រាប់ថា ទាន! លោកអ្នកមេនាងកន្យាចុះដើរសំដៅមកបន្ទប់នេះហើយ ប្រាកដជានឹងចូលមកបត់ជើងឥឡូវនេះ សូមលោកអញ្ជើញចេញមកឲ្យឆាប់ប្រយ័ត្នគេទាន់ ។

អាមាត្យនោះភិតភ័យឥតឧបមា ក៏បើកទ្វារចេញមកភ្លាម ។

កុមារជ័យ សូមលោកទៅពួនត្រង់ទីងងឹតឯណោះសិនទៅ កុំឲ្យគេមើលមកឃើញ ចាំអ្នកមេនាងស្ត្រីមកដល់សិនសឹមចេញមកជួបគ្នា ។

អាមាត្យក៏រត់ទៅពួនសម្ងំបំបាំងខ្លួននៅទីងងឹតនោះភ្លាម ។

កុមារជ័យ ធ្វើជារត់ទៅកាន់ទីបន្ទប់ ។ លុះបានមួយសន្ទុះកុមារជ័យក៏រត់ត្រឡប់មកប្រាប់ថា លោកនូវត្រង់ណោះមិនកើតទេ ព្រោះអម្បាញមិញអ្នកមេនាងកន្យាគាត់ថាឃើញមនុស្សរត់ស្ទូរមកកន្លែងនេះ ។ (នៅមានត)

# បុណ្ណកុមារ

(គ)

បំណែកខាងទសយុទ្ធ មេទ័ពនៃទេវគិរីនគរ លុះបានដឹងថា បុណ្ណមាណពកូនចិញ្ចឹមរបស់លោកត្រូវកងទ័ពនៃកល្យាណីបុរនគរចាប់ខ្លួនយកទៅបាន ក៏ខឹងខ្លាំងណាស់ លោកបានបញ្ជាការឲ្យកងទ័ពទាំងអស់ប្រុងប្រៀប ដើម្បីវាយប្រយុទ្ធទម្លាយកំពែងកល្យាណីបុរនគរឲ្យធ្លាយ ។ កងទ័ពទាំងអស់ក៏ប្រុងប្រៀបតាមបញ្ជា តែនៅមិនទាន់បានចូលទៅប្រយុទ្ធផង ក៏ស្រាប់តែទាហានសេះយកព្រួញដែលមានចុងរុំចងដោយសំបុត្រដែលគេបាញ់ចេញមកពីកំពែងនគរមកជូនលោកមេទ័ព ។

លោកមេទ័ពទសយុទ្ធទទួលយកសំបុត្រនោះមកមើល លុះមើលចប់សេចក្ដីហើយក៏ខឹងក្ដៅខ្លាំងណាស់ ស្ទើរតែមិនចង់ជឿ លោកបានអានសេចក្ដីក្នុងសំបុត្រនោះខ្លាំងៗម្ដងទៀតឲ្យពួកទាហានស្ដាប់ ។

“ ព្រះតេជគុណកុំជឿ ! ” វិស្សុកៈ នាយទាហានសេះដែលជាគូអាឃាតព្យាបាទរបស់បុណ្ណមាណពជម្រាបលោកមេទ័ព “ប្រសិនបើព្រះតេជៈគុណដកទ័ពថយទៅកាន់ទេវគិរីនគរវិញតាមពាក្យអង្វរករទទឹងជាស់តៀនក្នុងសំបុត្រនេះ មើលទៅដូចជាជំទាស់ព្រះរាជបំណងនឹងព្រះរាជបញ្ជារបស់ព្រះរាជាយើង ដែលព្រះអង្គមានបំណងចង់យាងមកដាក់កល្យាណីបុរនគរនៅចុងរដូវប្រាំងនេះ....”

“ ឈប់ ! ឈប់និយាយសិនវិស្សុកៈ! រឿងនេះមិនមែនជានាទីឯងដែលនឹងត្រូវមក

បញ្ចេញនូវយោបល់ទេ ” លោកមេទ័ពគំហកដោយសម្លេងខ្លាំង

“ តែខ្ញុំបានគិតថា បើអាបុណ្ណៈពជាព្រះរាជឱរសរបស់ព្រះរាជានៃនគរនេះពិតមែននោះ វាប្រហែលជាអ្នកស៊ើបការសឹកសម្ងាត់របស់ខ្មាំងសត្រូវ ក្លែងក្លាយបន្លំខ្លួនចូលមកស៊ើបការមើលកម្លាំងទាហានរបស់ពួកយើងមកយូរហើយ ”

“ ឈប់ស្រែកៈ ! ” លោកមេទ័ពគម្រាមម្ដងទៀត “យើងជាមេទ័ព មានអំណាចសិទ្ធិពេញទីអាចប្រហារអ្នកណាដែលជំទាស់នឹងយើងបានទាំងអស់ បុណ្ណមាណពនឹងជាអ្វីក៏ដោយ នាទីដែលយើងបានទទួលព្រះរាជឱង្ការមកនោះ ក៏យើងមិនផ្លាស់ប្ដូរប្រែប្រួលដាច់ខាត ទាហានទាំងឡាយ ! ចូរចោមវាយប្រយុទ្ធកំពែងនគរគលក្រណីបុរៈនេះឲ្យធ្លាយ អ្នកណាថយយើងនឹងកាត់ក្បាលចោល ! ”

លុះផុតពាក្យបញ្ជា ទាហានទាំងឡាយក៏ស្រែកឡើងថា ជយោ យ៉ាងគឹកកង ហើយក៏ដង្ហែក្បួនទ័ពចូលសម្រុកទៅវាយកំពែងនគរក្នុងពេលនោះភ្លាម

ចំណែកខាងកងទ័ពរបស់គលក្រណីបុរៈនគរដែលនៅលើកំពែងដ៏ខ្ពស់ លុះឃើញថាខ្មាំងសម្រុកប្រយុទ្ធចូលមកដូច្នោះ ក៏នាំគ្នាចោមបាញ់ព្រួញតម្រង់ទៅដូចគ្រាប់ភ្លៀង ដំរប្រេងដែលកំពុងពុះនៅក្នុងខ្ទះដែក ក៏ត្រូវដំកល់ប្រុងប្រៀបទុក ដើម្បីអាចជះដាក់ពួកទាហានខ្មាំងដែលសម្រុកឡើងមក ៗ ទាហាននៃទេវគិរីនគរមិនបានជាប្រយ័ត្នខ្លួនដោយយល់ថា ខាងលើនឹងបាចនូវគ្រួសឬខ្សាច់ចុះមក ក៏នាំគ្នាពាក់ពួក, ដូចការពារក្បាលហើយក៏ខំប្រវេប្រវាឡើងមក ៗ

ដំរ, ប្រេងដ៏ក្ដៅបានត្រូវគេសាចជះចុះមកហើយ ទាហានដែលមាននាទីបាញ់ព្រួញភ្លើងក៏បាញ់ភ្លាមបន្ទាប់បន្ទាន់គ្នានឹងការសាចជះដំរនឹងប្រេងនោះ ដំរនឹងប្រេងនោះ

ក៏ឆាបឆេះសន្ធោសន្ធៅឡើង ពេលខ្លួនទាហានខ្លាំងស្លាប់ដូចគេរាយពាយស្ទើរតែរាប់មិនអស់ ទីបំផុតកងទ័ពនៃទេវគិរីនគរត្រូវដកថយព្រោះមិនអាចទំនងវាយទម្លាយនូវកំពែងចូលទៅបាន...

ឯលោកមេទ័ពទសយុទ្ធឃើញពួកពលថយដូច្នោះខឹងខ្លាំងណាស់ ទើបស្រែកបញ្ជាឲ្យចូលទៅម្ដងទៀត ហើយខ្លួនលោកជិះសេះមុខទាហានចូលទៅទាល់តែជិតដល់កំពែងនគរ

នៅលើកំពែងនគរ រង្វង់ភ្នែកដ៏ថ្លាមុតនៃសត្យារាជឱរសទីពីររបស់ព្រះបាទសត្យារាជក្រឡេកមើលទៅស្រាប់តែឃើញលោកមេទ័ពទសយុទ្ធជិះសេះ ឈរនៅមិនឆ្ងាយពីកំពែងនគរប៉ុន្មានព្រះរាជកុមារក៏ប្រញាប់ប្រញាលទាញព្រួញ ដែលនៅក្នុងបំពង់ចងព្យួរពីខាងក្រោយព្រះបិដ្ឋចេញមកបាញ់តម្រង់ទៅភ្លាម

ព្រួញបានស្ទុះចេញពីបន្ទោះធ្នូហើយហោះហ្វឹងកាត់នូវដុំផ្សែងសំដៅទៅកាន់ចំណុចចំណងរបស់វាយ៉ាងត្រង់និងរហ័ស ទៅត្រូវត្រង់ដើមកលោកមេទ័ពទសយុទ្ធហើយមុតសាច់ធ្លុះចូលទៅខាងក្នុងយ៉ាងជ្រៅ លោកមេទ័ពភ្ញាក់ខ្លួនព្រើតហាក់ដូចជាមានអ្វីមួយពញាក់ហើយក៏ងាកមុខបែរទៅរកមើលត្រង់កន្លែងដែលព្រួញនោះហោះក៏ឃើញសត្យានេះដែលមានមុខមាមាត់ដូចបុណ្ណមាណពឥតខ្ចោះ លោកក៏ស្មានខុសថា ជាបុណ្ណមាណពហើយក៏ស្រែកដេរយ៉ាងខ្លាំងថា

„អាបុណ្ណ, ! អានេរគុណ ! „

ហើយក៏ប្រកាច់ដាច់ខ្យល់ធ្លាក់ពីលើខ្នងសេះស្លាប់ទៅ

(នៅមានត)

មួយសន្ទុះក្រោយមកនារីនោះក៏សិតនឹកឃើញដល់កន្ទុំថ្នាំដែលអ្នកជម្ងឺនេះទៅយកមក ៗ នាងបានទៅបើកកកាយហិបដែកមួយធំដែលនៅក្បែរថ្ងាមួយផ្ទុំសម្រាប់ដាក់ដបថ្នាំផ្សេងៗ នៅក្នុងហិបនេះពោរពេញទៅដោយថ្នាំគ្រប់បែបគ្រប់យ៉ាង តែនាងពុំសូវស្គាល់ថ្នាំទាំងនោះទេ ព្រោះអក្សរដែលបង្ហាញឈ្មោះថ្នាំសុទ្ធតែជាអក្សរជប៉ុនទាំងមានអក្សរអង់គ្លេសខ្លះផង ៗ ជាសំណាងខ្លះដែរនាងបានប្រទះឃើញដបថ្នាំសរ១ ទាំងធំៗជាច្រើន ដែលមានអក្សរនៅក្នុងនោះជាភាសាអង់គ្លេស ហើយនាងគាត់ស្មានខ្លះថានេះប្រហែលជាទឹកសមុទ្រ ៗ

នាងលើកដបថ្នាំនេះឡើងដោយមានអាការភ័យអរ មកពីហេតុថានាងស្គាល់ថ្នាំនៅមិនទាន់ច្បាស់, មុននេះនាងដាច់ចិត្តនឹងយកថ្នាំនេះមកប្រើតាមការស្មាន ហើយក៏បានយកប្រដាប់ប្រដាសម្រាប់បូមទឹកថ្នាំនេះចាក់បញ្ចូលសាច់ ហើយក៏ព្យាយាមបញ្ចូលថ្នាំនេះទៅលើស្បែកពោះអ្នកជម្ងឺឲ្យបានចំនួនជាពីរ-បីដបថ្នាំ ៗ កន្លះម៉ោងក្រោយមកនាងយកទឹកថ្នាំនេះមកបញ្ចូលពីរ-បីដបទៀតហើយក៏បន្ថែមដូចមុន ៗ

ប្រហែលជាបីម៉ោងក្រោយមកគេបានដឹងថាអ្នកជម្ងឺមានកំដៅដូចប្រក្រតីវិញហើយសរសៃឈាមក៏ពុំសូវលោតខ្លាំងដូចមុន, តែអ្នកជម្ងឺនៅស្ពុកស្ពឹងដដែល ៗ

សំណាងនឹងពពួកក្រុមរបស់នាយវិន្ទាទាំងប៉ុន្មាន ក៏កំពុងតែពិភាក្សាគ្នាពីការស្វែងរកនាយវិន្ទា, ចំពោះការពិភាក្សាគ្នានេះពុំសូវបានផលប៉ុន្មានទេ ដោយក្រុមទាំងអស់ចេះតែជំទាស់នឹងយោបល់របស់សំណាង ម្ល៉ោះហើយសំដីរបស់សំណាងដែលបានបង្ហាញហេតុផលហើយក៏ទៅជាការបដិសេធទៅវិញ ៗ

« ណ្ហើយគនយើង ! » ម្នាក់ទៀតជាដម្រួតវង់ឆ្លើយកាត់ឡើង « បើយើងអាវៀងតែទុកឲ្យវានិយាយរកហេតុផលពីនេះពីនោះច្រើនពេកទៅ ធ្វើម្ដេចនឹងមានពេលទៅស្វែងរកចៅហ្វាយនាយយើង គិតអាដែងមនុស្សបំណ្ហូលថ្មីនេះ វាជាសត្រូវនឹងយើងទេតើ ! ប្រហែលជាវាចង់ត្រួតយើងទេដឹង ! បើដូច្នេះយើងទាំងអស់គ្នាត្រូវតាមគ្នាទើបបាន ត្រូវប្រញាប់ឡើង ប្រមូលសម្ភារៈទាំងអស់ចេញពីទីនេះទៅតាមចៅហ្វាយយើង ជួបគ្នាត្រង់ណាយើងនៅត្រង់នោះតែម្ដងទៅជាការស្រេច ហើយកុំឲ្យអាដែងមុខក្រាសនេះតាមយើងតទៅទៀត ព្រោះតែវានេះហើយបានជាចៅហ្វាយយើងមិននៅ វាតែងធ្វើឲ្យចៅហ្វាយយើងមិនរកមុខពល់ថ្ងៃ បើតាមខ្ញុំ,មុននឹងយើងចេញទៅ,ត្រូវចាប់វាចងបង្អត់បាយចោលឲ្យស្លាប់នៅទីនេះតែម្ដង

សំដីប៉ុន្មានឃ្លានេះហើយដែលនាំឲ្យពួកក្រុមរបស់នាយវិន្ទាទាំងប៉ុន្មានកើតសេចក្ដីក្ដៅក្រហាយក្នុងចិត្តគ្រប់ៗ គ្នា ហើយក៏ចាប់ផ្ដើមសម្រេចការតាមបំណងនៃដម្រួតវង់នោះទៅ ។

ប្រហែលជាកន្លះម៉ោងក្រោយមក ដម្រុំទាំងឡាយក៏ត្រូវប្រមូលប្រដាប់ប្រដាចេញអស់ហើយដុតភ្លើងចោលតែម្ដង នៅត្រង់គល់ឈើធំមួយចំកណ្ដាលដម្រុំត្រូវចំណងយ៉ាងមាំពីទ្វាពង់កាយរបស់សំណាងយ៉ាងរឹងប៉ឹងដែលមិនអាចរើខ្លួនបានឡើង ។ ពេលនេះ សំណាងគ្មានអ្វីជាទីពឹងបានឡើយ អ្នកទ្រាំចាំតែសេចក្ដីស្លាប់ប៉ុណ្ណោះ លុះរាត្រីចូលមកដល់កាលណាអ្នករឹតតែភិតភ័យខ្លាំងណាស់ទៅទៀត ដោយខ្លាចអំណាចនៃសត្វសាហាវ ព្រោះទីនោះសម្បូណ៌ដោយសត្វសាហាវ ។

(នៅមានត)

រោងពុម្ពទរិយ

នៅខាងត្បូងផ្សារអូរឫស្សីសង្កាត់លេខ៥